# អង្គការសង្គមស៊ីវិលចំនួន៩ស្នើកុំឱ្យបើកការសុំកូនអន្តរប្រទេសរវាងកម្ពុជានិងអ៊ីតាលីឡើងវិញ




តាមរយៈសេចក្តីថ្លែងការណ៍នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣នេះ ក្រុមអង្គការសង្គមស៊ីវិលចំនួន៩ស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីតាលី បញ្ឈប់នូវការបើកសុំកូនអន្តរប្រទេសឡើងវិញដោយប្រទេសកម្ពុជាមិនបានអនុម័តកិច្ចគាំពារ ដែលនឹងការពារអត្ថប្រយោជន៍ល្អបំផុតរបស់កុមារ ឬទប់ស្កាត់ការកើតឡើងវិញនូវការក្លែងបន្លំ និងអំពើពុករលួយធ្ងន់ធ្ងរ ដែលបានកត់សម្គាល់នៅក្នុងការសុំកូនអន្តរប្រទេសដែលកើតមានពីអតីតកាល ។

ក្រុមអង្គការសង្គមស៊ីវិលទាំងនោះបន្តថា ប្រទេសជាច្រើន បានហាមឃាត់ការសុំកូនអន្តរប្រទេសពីប្រទេសកម្ពុជាពេញមួយទសវត្សរ៍ឆ្នាំ២០០០ បន្ទាប់ពីមានភស្តុតាងជាច្រើននៃការអនុវត្តដែលប្រាសចាកពីច្បាប់ និងគ្មានសីលធម៌ ។ នេះរួមបញ្ចូលទាំងអាជ្ញាធរ និងបុគ្គលិកមណ្ឌលកុមារកំព្រា ដែលក្លែងបន្លំឯកសារប្រកាសថា កុមារមួយចំនួនជាក្មេងកំព្រា ឬជាក្មេងគេបោះបង់ចោល ដោយជាទូទៅមានការផ្លាស់ប្តូរឈ្មោះ និងថ្ងៃខែឆ្នាំកំណើតរបស់ពួកគេ។ បន្ទាប់មក កុមារត្រូវបានគេសុំយកទៅចិញ្ចឹមនៅក្រៅប្រទេស ដោយពុំមានការយល់ព្រម ឬដឹងឮពីឪពុកម្តាយរបស់ពួកគេ។ ជាលទ្ធផល ប្រទេសកម្ពុជាខ្លួនឯងផ្ទាល់បានផ្អាកការសុំកូនអន្តរប្រទេសនៅក្នុងឆ្នាំ២០០៩ ។

ពាក់ព័ន្ធទៅនឹងបញ្ហានេះលោក តូច ចាន់នី អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានប្រាប់វិទ្យុវាយោនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣នេះថា លោកមិនទាន់បានទទួលសេចក្តីថ្លែងការណ៍របស់ក្រុមអង្គការសង្គមស៊ីវិលទាំងនោះនៅឡើយទេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការសុំកូនអន្តរប្រទេសរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលអ៊ីតាលី មិនអាចបញ្ឈប់បាននោះទេ ព្រោះធ្លាប់មានការចុះកុងត្រាជាមួយគ្នា។ សូមស្តាប់តាមការលើកឡើងរបស់លោកតូច ចាន់នី...

ទោះជាយ៉ាងនេះក្តី បើតាមសេចក្តីថ្លែងការណ៍រួមក្រុមអង្គការសង្គមស៊ីវិលទាំង៤មាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR), សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា(ADHOC), សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ(LICADHO) និង Intercountry Adoptee Voices (ICAV) បានឱ្យដឹងថា ប្រទេសកម្ពុជា និងប្រទេសអ៊ីតាលី មិនបានយកចិត្តទុកដាក់ចំពោះការអំពាវនាវរបស់អ្នកជំនាញនៃអង្គការសហប្រជាជាតិ និងសង្គមស៊ីវិល ក្នុងការស៊ើបអង្កេត និងដោះស្រាយការរំលោភបំពានកន្លងមកនោះទេ ដោយទុកឱ្យគ្រួសារ និងកុមារដែលត្រូវបានសុំទៅចិញ្ចឹមទាំងនោះ គ្មានមធ្យោបាយជួបជុំគ្នាវិញប្រសិនបើពួកគេចង់ភ្ជាប់ទំនាក់ទំនង ឬបង្ហាញការពិតឡើងវិញ។

គួរបញ្ជាក់ថា គណៈប្រតិភូមកពីគណៈកម្មាធិការសុំកូនអន្តរប្រទេសនៃប្រទេសអ៊ីតាលី បានជួបជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅក្នុងខែឧសភា ឆ្នាំ២០២៣ ដោយគណៈកម្មាធិការសុំកូនអន្តរប្រទេសអ៊ីតាលី បានរាយការណ៍ថា ភ្នាក់ងារសុំកូននៅអ៊ីតាលីចំនួន៣ ត្រូវបានអនុញ្ញាតឱ្យដំណើរការនៅប្រទេសកម្ពុជា ហើយការផ្តល់សិទ្ធិចំពោះភ្នាក់ងារចំនួន៣ផ្សេងទៀត គឺកំពុងស្ថិតនៅក្នុងការរង់ចាំ៕